# ព្រះពុទ្ធសាសនា



Document Produced by deskPDF Unregistered :: http://www.docudesk.com

# ព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនាជាសាសនាចង្អុលបង្ហាញប្រាប់អំពីហេតុផល និង ណែនាំអប់រំឱ្យសត្វលោកដើរនៅក្នុងផ្លូវត្រូវ គឺផ្លូវនៃសេចក្ដីសុខចម្រើនដែលសត្វលោកខ្លួនឯងប្រាថ្នាចង់បាន ព្រះ-ពុទ្ធសាសនាគឺជាផែនទីនៃជីវិតសត្វលោក ឯការប្រព្រឹត្តរបស់សត្វលោកគឺជាការដើរផ្លូវ ។

ព្រះពុទ្ធសាសនាបានបង្ហាញប្រាប់ផ្លូវនៃសេចក្ដីសុខមាន៣ប្រការគឺ ការមិនធ្វើនូវអំពើអាក្រក់ទាំងពួង១ ការបំពេញនូវសេចក្ដីល្អ១ និងការសម្អាតចិត្តរបស់ខ្លួនឱ្យបានស្អាតផូរផង់១ ។

## អំពីការមិនធ្វើនូវអំពើអាក្រក់ទាំងពួង

ការមិនធ្វើនូវអំពើអាក្រក់ទាំងពួង សំខាន់បំផុតគឺការមិនបៀតបៀនអ្នកដទៃ សេចក្ដីសុខដែលកើតមកពីការមិនបៀត-បៀនអ្នកដទៃ ជាសេចក្ដីសុខដ៏ធំទូលំទូលាយ និង ជាគ្រឹះនៃសេចក្ដីសុខថ្នាក់ខ្ពស់តទៅទៀតផង ។

មនុស្សយើងជាទូទៅ កាលដែលស្វែងរកនូវសេចក្ដីសុខ



សម្រាប់ខ្លួន រមែងស្វែងរកនូវវត្ថុដែលខ្លួនពេញចិត្ត វត្ថុដែលខ្លួនស្រឡាញ់ត្រូវការចង់បាន ដោយរួមប្រមូលនូវវត្ថុទាំងអស់មកវាស្ថិតនៅក្នុង៥ចំណុច ៖

១.រូបជាទីពេញចិត្តសម្រាប់ប៉ះនឹងភ្នែក

២.សំឡេងជាទីពេញចិត្តសម្រាប់ប៉ះនឹងត្រចៀក

៣.ក្លិនជាទីពេញចិត្តសម្រាប់ប៉ះនឹងច្រមុះ

៤.រសជាទីពេញចិត្តសម្រាប់ប៉ះនឹងអណ្ដាត

៥.ផោដ្ឋព្វៈជាទីពេញចិត្តសម្រាប់ប៉ះនឹងកាយ ។

ព្រោះហេតុតែសេចក្ដីត្រូវការនូវវត្ថុបំណង ដែលមាននូវចំណុចជាទីពេញចិត្ត៥មុខនេះ មនុស្សយើងក៏ចូលដល់ការបៀត-បៀនអ្នកដទៃ ដើម្បីដណ្ដើមយកនូវអ្វីៗដែលខ្លួនឯងពេញចិត្ត ។

ការបៀតបៀនអ្នកដទៃ វាកើតមកអំពីចិត្តដែលប្រាស-ចាកនូវសតិសម្បជញ្ញៈ ចិត្តឥតមេត្តា ចិត្តមិនមាននូវសេចក្ដីសុខស្ងប់ ព្រោះហេតុតែចិត្តមានសភាពវឹកវរជាទុក្ខយ៉ាងនេះហើយទើបបានបញ្ចេញនូវសកម្មភាព ធ្វើឱ្យអ្នកដទៃមានសេចក្ដីទុក្ខផងធ្វើឱ្យសង្គមជាតិវឹកវរមិនមាននូវសេចក្ដីសុខស្ងប់ផង ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

ដើម្បីការមិនបៀតបៀនអ្នកដទៃ មនុស្សយើងត្រូវតែអប់រំចម្រើននូវធម៌មេត្តាឱ្យមានក្នុងចិត្ត ដែលគេតែងហៅថា «មនុស្សមានធម៌ក្នុងខ្លួន» តាមពិត ចិត្តដែលមានមេត្តា ជាចិត្តមាននូវសេចក្តីសុខ មនុស្សយើងត្រូវចេះស្វែងរកសេចក្តីសុខពីក្នុងចិត្តរបស់ខ្លួនឯងផង កុំចេះតែស្វែងរកសេចក្តីសុខពីវត្ថុខាងក្រៅនោះ ព្រោះកាលណាបើមាននូវសេចក្តីសុខក្នុងចិត្តហើយក៏ព្រមឱ្យអ្នកដទៃបានសេចក្តីសុខផងដែរ បែបនេះសង្គមជាតិក៏រមែងមានសេចក្តីសុខស្ងប់ជាពិតប្រាកដ ។

ទឹកចិត្តមេត្តា គឺប្រាថ្នាឱ្យអ្នកដទៃបានសុខ បានចម្រើនកើនប្រយោជន៍ ដោយមានខ្លួនឯងជាឧបមា នៅពេលដែលនឹកគិតទៅរកបុគ្គលណា មេត្តាកើតឡើងប្រាថ្នាឱ្យបុគ្គលនោះបានសេចក្តីសុខ អប់រំចិត្តយ៉ាងនេះ ហ្វឹកហាត់គំនិតយ៉ាងនេះ រឿយៗជាប្រក្រតី ទោះជានៅក្នុងផ្ទះក្តី ទៅណាមកណាក្តី «សូមឱ្យអ្នកដទៃបានសេចក្តីសុខ »។

ការដែលមិនធ្វើនូវអំពើអាក្រក់ទាំងពួង ព្រោះមកអំពីមានសេចក្តីសុខនៅក្នុងចិត្ត សេចក្តីសុខនេះមានជាតិជាកុសល



ជាសេចក្តីសុខដែលប្រាសចាកគំនុំគុំគួន ប្រាសចាកការច្រណែន ប្រាសចាកគំនិតបៀតបៀន និងប្រាសចាកគ្រឿងសៅហ្មងរបស់ចិត្តផ្សេងៗទៀត ។

មនុស្សយើងម្នាក់ៗ រមែងមានទំនាក់ទំនងជាមួយអ្នកដទៃ ដូចជាមាតាបិតា និង បងប្អូនជាដើម កាលណាបើយើងប្រព្រឹត្តនូវអំពើឆ្គាំឆ្គង ជាអំពើដែលមនុស្សក្នុងសង្គមតិះដៀលឈ្មោះថា យើងបៀតបៀនដល់មាតាបិតា និង បងប្អូនរបស់យើងជាដើមដោយពិត ព្រោះធ្វើឱ្យមាតាបិតា និង បងប្អូនជាដើមនោះៗ មានទុក្ខផ្លូវចិត្តដោយខ្មាសអ្នកដទៃ ដូច្នេះហើយទើបអ្នកដែលមានមេត្តាធម៌ក្នុងខ្លួន មុននឹងធ្វើនូវអំពើអ្វីៗ តែងគិតពិចារណាដោយល្អិតល្អន់ មិនឱ្យអ្នកដទៃមានសេចក្តីទុក្ខព្រោះអំពើរបស់ខ្លួនឡើយ ។

ភរិយា និង ស្វាមីជួបគ្នាថ្មីថ្មោង ច្រើនដោយសេចក្តីស្រឡាញ់តាមបែបកិលេសក្នុងចិត្ត លុះដល់សេចក្តីស្រឡាញ់តាមបែបកិលេសក្នុងចិត្តនោះមានការថយចុះ ហើយមេត្តាមិនបានចូលមកជំនួសទេ បញ្ហាត្រូវបានកើតឡើង តែបើមានមេត្តាចូល

មកជំនួស ភរិយា និង ស្វាមីនោះរមែងរួមរស់ជាមួយគ្នាដោយសុខសាន្ត មិនមានការឈ្លោះទាស់ទែងបែកបាក់គ្នាឡើយ ។

មេត្តានាំឱ្យមនុស្សយើងមានសុជីវធម៌ និង សីលធម៌ក្នុងការរស់នៅ ធ្វើអ្វីៗតែងគិតក្រែងអ្នកដទៃមានសេចក្តីទុក្ខលំបាកដោយសារខ្លួន មិនត្រឹមតែប៉ុណ្ណោះ មេត្តានាំឱ្យមនុស្សយើងមានចិត្តរីករាយក្នុងការជួយអ្នកដទៃទៀតផង ។

កាលដែលចិត្តមិនទាន់មានការអប់រំ មិនទាន់ចម្រើនដោយអរិយធម៌ ចិត្តចេះត្រេកអរតែពីខាងបាននូវទ្រព្យសម្បត្តិផ្សេងៗ ចេះរីករាយក្នុងការទទួលយក តែមិនចេះត្រេកអររីករាយក្នុងការអស់ព្រោះឱ្យដល់អ្នកដទៃឡើយ លុះដល់ចិត្តបានទទួលការអប់រំ បានចម្រើនទៅដោយអរិយធម៌ ចិត្តក៏ចេះត្រេក-អររីករាយក្នុងការបរិច្ចាគជួយសង្គ្រោះដល់អ្នកដទៃផង មិនមែនចេះត្រេកអរតែពីខាងបានប៉ុណ្ណោះឡើយ ។

មាតាបិតាប្រាថ្នាប្រយោជន៍ដល់កូនប្រុសស្រី ធ្វើការងារបំពេញតួនាទីរបស់ខ្លួនសង្គ្រោះដល់កូនប្រុសស្រី លុះដល់បានឃើញកូនប្រុសស្រីមានសេចក្តីសុខ មាតាបិតាក៏មានចិត្តជាសុខ



ដូច្នេះ នៅក្នុងលោកនេះមិនមែនមានតែសុខព្រោះការបាននូវវត្ថុទាំងពួងនោះទេ គឺពិតជាមានសេចក្តីសុខព្រោះការបរិច្ចាគនូវវត្ថុទាំងពួងផងដែរ ដែលជាសេចក្តីសុខតាមផ្លូវចិត្តប្រកបទៅដោយមេត្តាធម៌ និង សេចក្តីសុខក្សេមផ្សេងៗទៀត តាមរយៈនៃការអប់រំចម្រើននូវកុសលធម៌ទាំងពួង ។

សូមមនុស្សទាំងឡាយក្រងនូវកុសលធម៌ ដើម្បីឱ្យខ្លួនបានទៅជាមនុស្សដ៏ល្អ ដូចជាអ្នកក្រងផ្កាបានរើសយកផ្កាដែលល្អៗមកក្រង សម្រេចបានទៅជាភួងមាលាដ៏ល្អ យ៉ាងនោះឯង ។

សូមមនុស្សទាំងឡាយស្វែងរកសេចក្តីសុខពីក្នុងចិត្តរបស់ខ្លួនឱ្យបានច្រើន សូមចេះត្រេកអរនឹងអំពើល្អរបស់ខ្លួន សូមកុំបៀតបៀនសត្វដទៃ និងសូមកុំធ្វើនូវបាបទាំងពួងឡើយ ។

## អំពីការបំពេញនូវសេចក្តីល្អ

ការមិនធ្វើនូវអំពើអាក្រក់ទាំងពួង ប្រៀបដូចជាការងូតទឹកសម្អាតកាយ ឯការបំពេញនូវសេចក្តីល្អ ប្រៀបដូចជាការស្លៀកពាក់និងប្រដាប់តាក់តែងកាយដោយអលង្ការ ។

ការបំពេញនូវសេចក្តីល្អ គឺការបំពេញនូវតួនាទី ហើយ





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

ការបំពេញនូវតួនាទីធ្វើឱ្យជីវិតមានគុណតម្លៃ ។

មនុស្សយើងម្នាក់ៗមានតួនាទីច្រើនយ៉ាង គឺតួនាទីជាមនុស្ស តួនាទីជាបុត្រធីតា តួនាទីជាភរិយា ឬជាស្វាមី តួនាទីជាមិត្ត តួនាទីជាមាតាបិតា តួនាទីជាបព្វជិត ។ល។ កិច្ចការក្នុងតួនាទីដែលត្រូវបំពេញយ៉ាងណានោះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងប្រាប់សព្វគ្រប់ទាំងអស់ ដូច្នេះ ដើម្បីបំពេញនូវតួនាទីរបស់ខ្លួនឈានឆ្ពោះទៅរកសេចក្តីសុខ មនុស្សគ្រប់គ្នាត្រូវសិក្សាព្រះធម៌ដែលជាពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធ ជាប្រយោជន៍ដើម្បីការយល់ត្រូវចំពោះការងារដែលត្រូវធ្វើ និង ដើម្បីតម្កល់ខ្លួនក្នុងតួនាទីដ៏ប្រពៃ ដែលជាមុខនាទីរបស់ខ្លួនពិតៗ ។

**គុណតម្លៃរបស់មនុស្សនៅត្រង់ការបំពេញតួនាទី** មនុស្សយើងមានជីវិតថ្លៃថ្នូរ ព្រោះធ្វើការតាមតួនាទីបានពេញលេញល្អបរិបូណ៌ មនុស្សដែលមិនបំពេញតួនាទីក៏រមែងជាមនុស្សមិនមានតម្លៃ ដូច្នេះមនុស្សគ្រប់គ្នាត្រូវតែយកចិត្តទុកដាក់ក្នុងតួនាទី ។

មនុស្សខ្ជិលដេកលក់មិនបានធ្វើការងារ មនុស្សឈឺក៏មិនបានធ្វើការងារ មនុស្សស្លាប់ក៏លែងបានធ្វើការងារអ្វីទាំងអស់



យ៉ាងណាមិញ មនុស្សដែលមិនបានបំពេញនូវតួនាទីរបស់ខ្លួនក៏ដូចជាមនុស្សខ្ជិលដេកលក់ មនុស្សឈឺ និងមនុស្សស្លាប់ យ៉ាងដូច្នោះដែរ ឬហៅថា «ស្លាប់ទាំងរស់ ស្អុយទាំងស្រស់ »។

មនុស្សយើងត្រូវតែព្យាយាមធ្វើសេចក្តីល្អឱ្យអស់ពីសមត្ថភាព បំពេញតួនាទីឱ្យបានពេញលេញបរិបូណ៌ ដើម្បីកពូននូវគុណតម្លៃនៃជីវិត ឱ្យជាមនុស្សល្អ ជាមាតាបិតាល្អ ជាកូនល្អ ជាគ្រូល្អ ជាសិស្សល្អ ជាភរិយាស្វាមីល្អ ជាមិត្តល្អ ជាចៅហ្វាយនាយល្អ ជាអ្នកបម្រើការល្អ ជាពុទ្ធបរិស័ទល្អ ជាប្រជាពលរដ្ឋល្អ និងឱ្យជាមនុស្សមានតម្លៃសម្រាប់សាសនា សម្រាប់សង្គមជាតិ។

ពុទ្ធសាសនិកជនដែលល្អ គឺជាអ្នកដែលបានបំពេញតួនាទីយ៉ាងខ្ជាប់ខ្ជួន ចំពោះបព្វជិតត្រូវបំពេញនូវគន្ថធុរៈ និង វិបស្សនាធុរៈព្រមដោយការពន្យល់ប្រាប់អំពីព្រះពុទ្ធសាសនា ដល់ឧបាសក និង ឧបាសិកាទៀតផង ចំណែកគ្រហស្ថ ជាឧបាសក ជាឧបាសិកា ត្រូវខ្វល់ខ្វាយបំពេញកិច្ចការទំនុកបម្រុងព្រះសាសនាដោយមុឹងម៉ាត់ មកវត្តដើម្បីជួយកិច្ចការរបស់វត្តឱ្យបានពេញដៃពេញជើង ធ្វើការដោយចិត្តស្មោះត្រង់ ត្រូវកសាងខ្លួនឱ្យទៅជា

Document Produced by deskPDF Unregistered :: http://www.docudesk.com

ធនធានដ៏សំខាន់របស់ព្រះពុទ្ធសាសនា ។

កូនដែលជាមនុស្សមានតម្លៃរបស់ឪពុកម្តាយ គឺកូនដែលធ្វើឱ្យឪពុកម្តាយសប្បាយចិត្ត ជាកូនដែលឪពុកម្តាយស្រឡាញ់ដោយក្តីសង្ឃឹម ព្រោះខ្លួនជាកូនបានបំពេញតួនាទីល្អ ។

អ្នកណាជាមនុស្សដែលឆ្លាត រៀនល្អ រៀនពូកែ ធ្វើប្រយោជន៍ឱ្យដល់ប្រទេសជាតិ ធ្វើឱ្យលោកគ្រូអ្នកគ្រូសប្បាយចិត្ត រីករាយដោយបានគិតឃើញថា អាត្មាអញបានផលិតមនុស្សឱ្យមានប្រយោជន៍ដល់ប្រទេសជាតិ អ្នកនោះឯងគឺជាសិស្សដែលមានគុណតម្លៃដ៏ថ្លៃថ្លារបស់សាលារៀន ។

មិត្តដែលមានគុណតម្លៃ គឺជាមិត្តដែលនាំមិត្តឱ្យផុតពីនរក និង សេចក្តីក្តៅក្រហាយផ្សេងៗ ជួយការពារមិត្តឱ្យបានរួចផុតពីអន្តរាយ ណែនាំមិត្ត ដាស់តឿនមិត្ត បបួលមិត្តមករកគុណធម៌ឱ្យមិត្តស្តាប់ធម៌ដែលជាគ្រឿងអប់រំចិត្ត ។

ម្យ៉ាងទៀត **មនុស្សដែលមានតម្លៃគឺមនុស្សដែលពឹងបាន** ដំបូលផ្ទះមានតម្លៃព្រោះធ្វើឱ្យយើងពឹងបាន ដោយបិទបាំងនូវកម្តៅថ្ងៃ និងទឹកភ្លៀងជាដើម ទោះជាអ្វីៗទៀតក៏ដោយ ឱ្យតែ



ជាទីពឹងបាន គឺសុទ្ធតែជារបស់មានតម្លៃទាំងអស់ យ៉ាងណាមិញមនុស្សយើង ដែលកើតមកហើយ អាចជាទីពឹងបានដល់អ្នកដទៃ ឬឱ្យអ្នកដទៃពឹងបាន គឺជាមនុស្សមានតម្លៃ យ៉ាងនោះឯង ។

មាតាបិតាមានតម្លៃដ៏ក្រៃលែង ព្រោះជាទីពឹងរបស់កូនដែលនៅតូចៗ លុះដល់កូនធំឡើង មាតាបិតាពឹងកូនបានវិញ កូនក៏មានតម្លៃដល់មាតាបិតាដែរ ដូច្នេះ មនុស្សយើងកើតមកត្រូវធ្វើឱ្យបានពីរចំណុចសំខាន់គឺ មួយជាទីពឹងនៃអ្នកដទៃ ពីរជាបុគ្គលដែលគេគួរបូជា (អាមិសបូជា និងបដិបត្តិបូជា ) តាមពិតមនុស្សដែលជាទីពឹង គឺមនុស្សដែលគួរគេបូជាហ្នឹងឯង ដូចជាសាសនាជាទីពឹង ទើបមនុស្សគោរពបូជាសាសនា ។

ការបំពេញនូវអំពើល្អគ្រប់យ៉ាង គឺដើម្បីធ្វើខ្លួនឱ្យបានជាទីពឹង យ៉ាងហោចណាស់ក៏ត្រូវឱ្យបានជាទីពឹងនៃខ្លួនឯងដែរ។

## អំពីការសម្អាតចិត្តរបស់ខ្លួនឱ្យបានស្អាត

ការមិនធ្វើនូវបាបទាំងពួង ប្រៀបដូចអ្នកឈឺរៀរចំណីទាស់ ការបំពេញនូវសេចក្តីល្អ ប្រៀបដូចអ្នកឈឺបរិភោគអាហារបំប៉នសុខភាព ឯការសម្អាតចិត្តរបស់ខ្លួនឱ្យបានស្អាត ប្រៀបដូច

អ្នកឈឺលេបថ្នាំកម្ចាត់បង់នូវរោគឱ្យបានជាសះស្បើយ ។

ការសម្អាតចិត្តឱ្យស្អាត អាស្រ័យដោយបញ្ញាយល់ដឹងអំពីការពិតនៃជីវិត បញ្ញាធ្វើកិច្ចកម្ចាត់បង់នូវគ្រឿងសៅហ្មងរបស់ចិត្ត ដូច្នេះក្នុងជីវិតរាល់ថ្ងៃត្រូវអប់រំចម្រើនបញ្ញា ។

ការពិតនៃជីវិត គឺរមែងមានលាភ រមែងអត់លាភ រមែងមានយស រមែងអត់យស រមែងមានគេសរសើរ រមែងមានគេនិន្ទា រមែងមានសុខ រមែងមានទុក្ខជាធម្មតា តែព្រោះមិនដឹងការពិតនៃជីវិត ចិត្តក៏រមែងចម្រើនទៅដោយគ្រឿងសៅហ្មង ។

ការសិក្សាអំពីសេចក្តីពិតនៃជីវិត ដោយយោនិសោមន-សិការ ជាហេតុនាំឱ្យចម្រើននូវបញ្ញា ។

យោនិសោមនសិការ គឺឆ្លាតក្នុងការពិចារណា បានដល់ការពិចារណារកហេតុនៃអ្វីៗដែលបានកើតឡើង ព្រោះអ្វីៗដែលបានកើតឡើងក្នុងជីវិត សុទ្ធតែត្រឹមត្រូវពិតទៅតាមហេតុ ។

ហេតុផលជាច្បាប់ធម្មជាតិ ជាការពិតនៃជីវិត ជាសច្ចធម៌ជាធម្មៈដែលសម្រាប់សិក្សា ដូច្នេះហើយ យើងត្រូវកែប្រែពីការញាប់ញ័រចំពោះសេចក្តីពិតនៃជីវិត ត្រឡប់មកជាការសិក្សាអប់រំ



ចម្រើនប្រាជ្ញាស្មារតី ក្នុងសេចក្តីពិតនៃជីវិតវិញ ។

នៅពេលបានលាភបានយស ក៏ប្រើលាភយសនោះឱ្យបានសម្រេចជាប្រយោជន៍ដល់ខ្លួនឯងនិងអ្នកដទៃ បានពាក្យសរសើរក៏មានស្មារតី មិនស្រវឹងវង្វេង ហើយក៏មានកម្លាំងចិត្តប្រព្រឹត្តការងារជាប្រយោជន៍តទៅទៀត បានសុខហើយក៏រក្សានូវហេតុនៃសេចក្តីសុខនោះ និងចែកចាយសេចក្តីសុខឱ្យទូលំទូលាយដល់អ្នកដទៃផងទៀត តែបើអត់លាភ ឬវិនាសទ្រព្យ អត់យស ឬអស់យស និន្ទាទុក្ខមកដល់ ត្រូវកំណត់ដឹងថា នេះជាការពិតនៃជីវិត ហើយត្រូវសិក្សាដោយយោនិសោមនសិការ ឱ្យសម្រេចបាននូវប្រយោជន៍ដ៏សំខាន់មកវិញ កាលណាបើអប់រំបានយ៉ាងនេះ អ្វីៗដែលបានមកដល់ជីវិត គឺសុទ្ធតែញ៉ាំងប្រយោជន៍ឱ្យសម្រេចបានទាំងអស់ ដូច្នេះជីវិតមានតែការចម្រើនទៅដោយប្រយោជន៍។

សេចក្តីស្រឡាញ់ដោយឆន្ទរាគៈ ជាហេតុនៃសេចក្តីទុក្ខប៉ុន្តែមានមនុស្សច្រើននាក់យល់ថា សេចក្តីស្រឡាញ់បែបនេះ ជាហេតុនៃសេចក្តីសុខនិងនាំឱ្យជីវិតមានន័យទៅវិញ បើវត្ថុជាទីស្រឡាញ់មានការវិនាសទៅ គេក៏មានសេចក្តីទុក្ខសោកដែរ តែ





Document Produced by deskPDF Unregistered :: http://www.docudesk.com

នេះគេយល់ថា ទុក្ខសោករបស់គេកើតឡើង ព្រោះហេតុតែវត្ថុនោះឯងមានការវិនាសទៅតែប៉ុណ្ណោះ ដោយគេពុំបានឃើញតាមសេចក្តីពិតថា ការស្រឡាញ់ដោយឆន្ទរាគៈនេះជាហេតុនៃសេចក្តីទុក្ខសោកឡើយ ។

នៅពេលដែលបាត់បង់អ្វីៗ ដែលជាទីស្រឡាញ់ពេញចិត្ត សត្វលោករមែងមានសេចក្តីទុក្ខសោក នេះគឺជាការបាត់បង់នូវសេចក្តីសុខតាមផ្លូវចិត្ត ។ សត្វលោកពុំបានឃើញទោសចំពោះរបស់ដែលជាទីស្រឡាញ់ឡើយ សត្វលោកខំប្រឹងស្វែងរកនូវអ្វីៗដែលបានបាត់ទៅនោះ ដោយប្រើគ្រប់មធ្យោបាយ រហូតហ៊ានធ្វើនូវអំពើទុច្ចរិតទៀតផង នេះព្រោះសត្វលោកយល់ថា សេចក្តីសុខរបស់ខ្លួនវាស្ថិតនៅក្នុងរបស់ដែលបាត់ទៅនោះឯង ។

សត្វលោកដែលមិនបានសិក្សាអំពីការពិតនៃជីវិត រមែងញាប់ញ័រដូចត្រីនៅក្នុងទីដែលមានទឹកតិច សត្វលោកផ្ញើសេចក្តីសុខរបស់ខ្លួនតែជាមួយនឹងរបស់ខាងក្រៅ ម៉្លោះហើយចិត្តរបស់សត្វលោកត្រូវសៅហ្មងជានិច្ចដោយឆន្ទរាគៈ ទាំងដែលសៅហ្មងព្រោះការមិនបានឃើញទោសនៃឆន្ទរាគៈទៀតផង ។



ការសិក្សាអំពីសេចក្តីពិតនៃជីវិត កំណត់ដឹងចំពោះរបស់ដែលមិនទៀង រមែងនាំឱ្យឃើញទោសនៃឆន្ទរាគៈដែលជាហេតុនៃសេចក្តីទុក្ខ និងនាំឱ្យចិត្តស្អាតផូរផង់មានភាពភ្លឺស្វាង ។

ការពិតនៃជីវិតជាច្បាប់ហេតុផល ផលរមែងប្រព្រឹត្តទៅតាមហេតុ ដូច្នេះកិច្ចរបស់បញ្ញាក្រៅអំពីធ្វើការសម្អាតចិត្តឱ្យស្អាតផូរផង់នោះ បញ្ញានៅមានកិច្ចសាងហេតុនៃសេចក្តីសុខក្នុងជីវិតបានយ៉ាងសម្បូណ៌ទៀតផង ព្រោះបញ្ញាបានយល់អំពីហេតុផលនៃធម្មជាតិ ។

## សរុបប្រយោជន៍នៃព្រះពុទ្ធសាសនា

ការមិនធ្វើអំពើអាក្រក់ទាំងពួង បានផ្តល់ឱកាសដល់ការបំពេញសេចក្តីល្អ ឯការបំពេញសេចក្តីល្អមានឧបការៈដល់ការសម្អាតចិត្តរបស់ខ្លួន ជាទីបំផុតនៃព្រហ្មចរិយធម៌ទាំងបីមុខនេះ គឺចិត្តស្អាតផូរផង់ហ្នឹងឯង ចិត្តស្អាតផូរផង់មានប្រយោជន៍ដល់ការឈ្នះអស់នូវទុក្ខទាំងពួង ។

## សង្ខេបខ្លឹមសារព្រះពុទ្ធសាសនាចប់តែប៉ុណ្ណោះ





Document Produced by deskPDF Unregistered :: http://www.docudesk.com

## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការខារធម្មទាន

| | |
|---|---|
| ១_ឧបាសក សំរ៉ង វណ្ណ | ២_ឧបាសក យន្ត សួន |
| ៣_ឧបាសក គួង លាងផេង | ៤_ឧបាសក មួង យេន |
| ៥_ឧបាសក រស់ សូផាត | ៦_ឧបាសក គុយ សុធន |
| ៧_នាង ជា សុណារី | ៨_នាង ឃុន សូនីម៉ា |

## រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
## ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយធម៌ប្រចាំឆ្នាំ

១_ ឧបាសក យូស៊ាង_ងួនលី និង ឧបាសិកា លីម_ឃីម

២_ ឧបាសក ឆាយ_អ៊ីវស៊ាង និងឧបាសិកា ហុង_គឹមសែ

៣_ ឧបាសកឆាយអ៊ីវ_ស្រេងលីម និងឧបាសិកាហួត_ឃីម

៤_ ឧបាសកហៃ_ប៊ុនណារិន និងឧបាសិកាអោង_ស៊ីថាន់

៥_ ក្រុមឧបាសក ឈុំ_កុសល និងឧបាសក អ៊ុន_ឆាយគ្រី

៦_ ក្រុមឧបាសក លឹម _ស៊ាង ( ហៅ ទូច )



៧_ ឧបាសក យន្ត_ សួន និងភរិយា ព្រមទាំងបុត្រ

៨_ ឧបាសក ប៊ុន_ហេង ឧបាសិកា ជុំ_សុខុម ព្រមទាំងបុត្រ

៩_ ឧបាសិកា ឱម_លក្ខណា ព្រមទាំងបុត្រ

១០_ ឧបាសិកា ញឹក_ប៊ុនថា និងឧបាសិកា ម៉ែន_សុភារី

១១_ ឧបាសិកា ច័ន្ទ_បុប្ផាណា ព្រមទាំងបុត្រ

១២_ ឧបាសិកា ស្រង់_ឡេង ព្រមទាំងបុត្រ

១៣_ ឧបាសក អ៊ុត _ឆៃវ៉ាន និងភរិយា ព្រមទាំងបុត្រ

១៤_ ឧបាសក ប្លោក _ងួនថៃ និងភរិយា ព្រមទាំងបុត្រ

១៥_ ឧបាសក ជឹម _អេងស្រ៊ន និងភរិយា ព្រមទាំងបុត្រ

១៦_ ក្រុមឧបាសក មួង _យេន (វត្តសំពៅមាស )

១៧_ ឧបាសិកា ជី_ឡាង

១៨_ លោកម៉ៅ_សុគន្ធ អ្នកស្រី យ៉េក_ហួយ ព្រមទាំងបុត្រ

១៩_ លោកយាយ ម៉េង_ហ៊ន

២០_ ឧបាសក សំរ៉ង_វណ្ណ និងឧបាសិកា សេង_គីមលន់

២១_ ឧបាសិកា សេង_ឃីម

២២_ លោក សេង_រ៉ានី និងអ្នកស្រី ណារិន

២៣_ ឧបាសិកា ហេង_ស៊ីវខេង និងម្ដាយឈ្មោះ អៀង_ហ៊ិច





Document Produced by deskPDF Unregistered :: http://www.docudesk.com

២៤. លោក យឹម-ស៊ីមុន្នី និងអ្នកស្រី យូ-ប៉ូលីន ព្រមទាំងបុត្រ

២៥. ឧបាសក ឡាយ-សុខុម និងឧបាសិកា សួន-ចន្ថា ព្រមទាំងបុត្រ

២៦. ឧបាសក ធឹម-ញាណ និងឧបាសិកា កាំង-ប៉ូលីន ព្រមទាំងបុត្រ

២៧.ឧបាសិកា អ៊ំ-អ៊ន់

២៨. ឧបាសិកា ធម្មិកា

២៩. ឧបាសិកា មូនី-សុខ

៣០. ឧបាសិកា តាំង-គីមហួ

៣១. ឧបាសក ស៊ុន-តាំងម៉ាប

៣២. ឧបាសិកា ប៉ូអាន-ស៊ីវត្ថា

៣៣. ឧបាសិកា ប៉ូផាវ៉ាណ

៣៤. ឧបាសិកា តឹក-សារឿន ព្រមទាំងកូនចៅទាំងអស់

៣៥. ឧបាសិកា លីម-ឆេងហ្គិច ព្រមទាំងបុត្រ

៣៦. ឧបាសិកា សាក់-ស៊ាងអេង

៣៧. ឧបាសិកា ជា-ផាត ព្រមទាំងបុត្រ

៣៨. ឧបាសក ប៉ុល-នាង និងឧបាសិកា គ្រៀល-ស៊ីយ៉ា ព្រមទាំងបុត្រ

៣៩. ឧបាសិកា គា-ស៊ីន

៤០. ពុទ្ធបរិស័ទ សុខ-ចាន់រី និង ភឿក-កុម្ភ

៤១. ឧបាសិកា កង- ភីម



៤២. ឧបាសិកា អ៊ឹម - ស៊ីវន

៤៣. ឧបាសិកា រស់ -លីណា

៤៤. ឧបាសិកា យូ - ណូសណារី

៤៥. ឧបាសក អ៊ុក-សាម៉ាណារ៉ា ឧបាសិកាហ៊ាប-តេង ព្រមទាំងបុត្រ

៤៦. ឧបាសក ម៉ៅ-ស្រ៊ិន ឧបាសិកា ទូច-ស៊ីនហ៊ន ព្រមទាំងបុត្រ

៤៧. ឧបាសក ពុធ-ប៉ោលាង ឧបាសិកា ហ៊ុន-ស៊ីវអៀង

៤៨. ឆែមសុក្រឹត +ពុធគន្ធា Chhem Sokreth et Puth Kunthea

៤៩. ឧបាសក ម៉ែន-សឿន ឧបាសិកា អៀង-ណារី ព្រមទាំងបុត្រ

៥០. ក្រុមពុទ្ធបរិស័ទនៅទីក្រុងស៊ីតនី ប្រទេសអូស្ត្រាលី

៥១. ក្រុមពុទ្ធបរិស័ទចិត្តបុណ្យក្នុងសហគមន៍ធម្មទាន

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទានឈ្នះអស់ទានទាំងពួង

**បោះពុម្ព ៥០.០០០ ក្បាល**
**សម្រាប់ជាធម្មទាន**





Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

# ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌

## ព្រះពុទ្ធសាសនា

## ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត-ក្រុង | ពេលផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| រាជធានីភ្នំពេញ | -05h00 mn<br>-19h00 mn<br>-19h30 mn<br>-19h30 mn<br>-20h00 mn<br>-20h30 mn | -FM 99 MHz<br>-AM 918 MHz<br>-FM 95 MHz<br>-FM 97 MHz<br>-FM 98 MHz<br>-FM 107 MHz |
| ក្រុងព្រះសីហនុ | -06h30 mn<br>-13h30 mn | -FM 92 MHz |
| ខេត្តបាត់ដំបង | -06h20 mn<br>-17h30 mn | -FM103.2MHz<br>-FM 91 MHz |
| ក្រុងប៉ៃលិន | -18h00 mn | -FM 90 MHz |
| ខេត្តសៀមរាប | -18h30 mn | -FM100.5MHz |
| ខេត្តពោធិសាត់ | -06h00 mn | -FM 98.5MHz |

**សុខា សទ្ធម្មទេសនា**

កិរិយាសម្តែងនូវព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ



# សៀវភៅដែលរៀបរៀងដោយ

## ខ្ញុំព្រះករុណា ខ្ញុំបាទ

## ប៊ុត-សាវង្ស

១-ព្រះពុទ្ធសាសនា

២-ជំនួយសតិភាគ ១ ដល់ភាគ៧

៣-មនុស្សជាមួយនឹងការងារ

៤-សិក្ខាបទមនុស្សល្អ

៥-ពរ៤ប្រការ

៦-ព្រះពុទ្ធភាសិត ៤៣គាថា

៧-ខ្លឹមសារគួរយល់ដឹង

**ហនន្តិ ភោគា ទុម្មេធំ នោ ច បារគវេសិនោ**

ភោគៈទាំងឡាយ តែងសម្លាប់នូវបុគ្គលល្ងង់ខ្លៅ តែមិនសម្លាប់នូវបុគ្គលដែលស្វែងរកត្រើយ គឺព្រះនិព្វានឡើយ ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

# ពាក្យប្រារព្ធ

ឆ្លៀតឱកាសក្រោយអំពីការបិទវគ្គសិក្សាព្រះធម៌ឆ្នាំទី ១៣ នៅរាជធានីភ្នំពេញ និងមុនពេលធ្វើដំណើរទៅស្រុកកំណើត នៅខេត្តបាត់ដំបង ខ្ញុំព្រះករុណាខ្ញុំបាទបានសរសេរសៀវភៅដ៏ស្តើងនេះទុកជាធម្មទាន មានឈ្មោះថា " **ព្រះពុទ្ធសាសនា** " ខ្ញុំសរសេរដោយសេចក្តីសង្ខេប និងជាពាក្យសម្រាយៗ សម្រាប់មនុស្សគ្រប់វ័យដែលអាចអានអក្សរខ្មែរបាន ។

តើព្រះសម្មាសម្ពុទ្ធទូន្មានសត្វលោកយ៉ាងណា? តើព្រះពុទ្ធសាសនាប្រដៅសត្វលោកឱ្យប្រព្រឹត្តដូចម្តេច? កូនសៀវភៅនេះមិនក្រាស់មែន តែអាចបកស្រាយបាននូវបញ្ហានេះ ព្រោះសៀវភៅនេះឯង បានសម្តែងអំពីគោលព្រះពុទ្ធសាសនាបីយ៉ាងសំខាន់ៗ ដូច្នេះសូមពុទ្ធបរិស័ទរីករាយជ្រះថ្លាក្នុងការអាន និងសូមឱ្យបានចាំទុកនូវសេចក្តីនៃព្រះធម៌ ដើម្បីជាប្រយោជន៍ដល់ការបដិបត្តិកម្ចាត់នូវសេចក្តីសៅហ្មងក្នុងជីវិតរបស់ខ្លួន ។



សូមឧទ្ទិសនូវកូនសៀវភៅដ៏ស្តើងនេះជាសក្ការបូជាថ្វាយចំពោះព្រះរតនត្រ័យ សូមបុណ្យកុសលបានសម្រេចដល់មាតាបិតារបស់ខ្ញុំ គឺលោកឪពុក **ម៉ុត-ឆួត** និងអ្នកម្តាយ **ឡុញ-អឿន** ដែលបានចែកឋានចាកលោកនេះទៅហើយ មួយអន្លើដោយពពួកញាតិ ព្រមទាំងអ្នកដែលកំពុងកាន់អាននូវសៀវភៅនេះ ។

មនុស្សយើងមិនអាចបាននូវអ្វីៗគ្រប់យ៉ាង ទៅតាមការស្រេកឃ្លានដោយអំណាចតណ្ហារបស់ខ្លួនឡើយ ដូច្នេះដើម្បីកុំឱ្យខ្លួនឯងស្លាប់ទៅទាំងការខ្វះខាតរហេមរហាម គឺត្រូវតែប្រញាប់រៀនឱ្យចេះត្រេកអរនឹងរបស់ដែលខ្លួនកំពុងមាននេះឯង ។

សូមមនុស្សគ្រប់គ្នាស្វែងរកសេចក្តីសុខ តាមការណែនាំរបស់ព្រះពុទ្ធ កុំស្វែងរកសុខពីការស្រេកឃ្លាននៃអ្នកដទៃឡើយ។

**ភ្នំពេញ ថ្ងៃ២កើត ខែឧត្តិយាសាឍ**<br>**ឆ្នាំមមី ចត្វាស័ក ព.ស. ២៥៤៦**<br>**ខ្ញុំព្រះករុណា ខ្ញុំបាទ ម៉ុត-សាវឌ្ឍ**